## Complimenting someone



១ តារា៖ នារី ទៅណាហ្នឹង? តែងខ្លួនស្អាតម៉េះ?

នារី៖ អូ ខ្ញុំទៅខួបកំណើតគេបង។ ម៉េចដែរអាវហ្នឹង? អត់អីណាអីបង?

តារា៖ ប៉ុណ្ណឹងស្អាតហើយ! ឃ្យូត!

នារី៖ ឃ្យូតទៀត! អរគុណ បង។ អីចឹង ខ្ញុំទៅហើយណា បាយៗ។

២ នារី៖ បង ឯកសារម្សិលមិញខ្ញុំបកប្រែហើយអស់ហើយណា។

តារា៖ ហ្នឹងអ៎? ធ្វើការលឿនអ៉ានៀកនារី។ អីចឹងជួយសួរកញ្ញាមើល បកហើយនៅ។ ម្សិលមិញបងឲ្យនារីបកពាក់កណ្ដាល ឲ្យកញ្ញាបកពាក់កណ្ដាល។

នារី៖ ចំាស ខ្ញុំដឹងតាសបង។ ខ្ញុំឃើញកញ្ញារវល់ ខ្ញុំសុំយកមកបកទាំងអស់ម៉ងទៅ។ អីចឹង ហើយអស់ហើយបង។

តារា៖ ធ្វើការលឿនហើយចិត្តល្អទៀត។ មិនងាយរកបានអ៉េនៀក។ អរគុណ នារី។

នារី៖ ចំាសបង។ អត់អីទេ មិនសូវជាច្រើនម៉ានផង។

| | |
|---|---|
| នារី / កញ្ញា / តារា | female / female / male Cambodian name |
| ទៅណាហ្នឹង? | Where are you going? |
| តែងខ្លួន | to get dressed, to adorn/beautify/decorate oneself |
| ម៉េះ | spoken form of ម្ល៉េះ |
| អត់អីណាអី? | It’s alright/ok/fine, isn’t it? |
| ឃ្យូត | cute, also: គួរឲ្យស្រឡាញ់ |
| បក, បកប្រែ | to translate |
| ហើយអស់ហើយ | everything is done/finished |
| ហ្នឹងអ៎? | Really? |
| ធ្វើការលឿនអ៉ានៀក | you work so fast! |
| ម៉ង | spoken form of តែម្ដង = right away, immediately |
| មិនងាយរកបានអ៉េនៀក | [a person like you] is not so easy to find! |
| មិនសូវ ... ម៉ាន | not very ..., not so much ...; ម៉ាន is here the spoken form of ប៉ុន្មាន |

Copyright © 2018 www.aakanee.com – This document is provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

## Cultural notes

ពាក្យថា បញ្ជោរ មានន័យថា និយាយសរសើរនរណាម្នាក់អំពីអ្វីដែលមិនពិត ដូចជា មិនស្អាតក៏សរសើរថាស្អាត ។ល។ រីឯ អ្នកដែលចូលចិត្តស្តាប់ពាក្យបញ្ជោរ គេហៅថាមនុស្សស៊ីជោរ។ ហើយក៏មានមនុស្សដែលនៅមុខសរសើរ នៅក្រោយនិយាយដើមដែរ។ ផ្ទុយទៅវិញ ក៏មានមនុស្សដែលមិនចេះសរសើរនរណា ទោះគេធ្វើបានល្អក៏ដោយ។

| | |
|---|---|
| ។ល។ | etc. |
| ស៊ីជោរ | refers to someone who likes to be flattered/praised |
| នៅមុខសរសើរ<br>នៅក្រោយនិយាយដើម | praising you to your face, but speaking ill about you behind your back |
| ផ្ទុយទៅវិញ | on the contrary |
| ទោះ ... ក៏ដោយ | even though ... |

## Additional dialogue

វិបុល៖ តារា របាយការណ៍ហ្នឹង អ្នកណាអ្នកធ្វើ? រៀបចំបានល្អអ៊ំា។
តារា៖ នារីបង។ គ្នាខំស្រាវជ្រាវរកព័ត៌មានថែមផងអីផង។ នុះ នារីអ៊ំ! នារីម៉ោនេះតិច។
នារី៖ ចំាសបង។
តារា៖ បងវិបុលថានារីឯងធ្វើរបាយការណ៍បានល្អអ៊ំាណា។
វិបុល៖ ហ្នឹងហើយ ច្បាស់លាស់ហើយស្រួលយល់ទៀត។
នារី៖ អរគុណច្រើនបង។ ម៉ោពីខ្ញុំចង់ដឹងដែរ ចេះតែស្រាវជ្រាវលេងៗទៅ។
វិបុល៖ មនុស្សចូលចិត្តស្រាវជ្រាវអីចឹង ភាគច្រើនមនុស្សឆ្លាត។ អីចឹង នារីជួយធ្វើរបាយការណ៍លើកក្រោយផងណា។ នារីអ្នកធ្វើរបាយការណ៍ ខ្ញុំទុកចិត្តហើយ។
នារី៖ អរគុណបង។

| | |
|---|---|
| វិបុល | male Cambodian name |
| របាយការណ៍ | report |
| អ៊ំា | spoken form of ណាស់ = very |
| គ្នា | he/she (expressing positive feelings towards the person) |
| ស្រាវជ្រាវ | to do research |
| ... ផងអីផង | ... and other things |
| ម៉ោនេះតិច | please come here! |
| ម៉ោពី | spoken form of មកពី = because |
| ចេះតែ ... ទៅ | I just did ... [without thinking/reflecting/hesitating too much] |
| ទុកចិត្ត | to trust, to have confidence in |

Copyright © 2018 www.aakanee.com – This document is provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.